# កិច្ចតែងការបង្រៀន

កាលបរិច្ឆេទ ៖ ថ្ងៃ..................ទី .................. ខែ .................... ឆ្នាំ ......................

មុខវិជ្ជា ៖ វិទ្យាសាស្ត្រ

ប្រធានបទ ៖ ប្រតិបត្តិដោយសុវត្ថិភាព

សកម្មភាពគោល ៖ សង្កេត

ចំណងជើង ៖ ស្លាកសញ្ញាផ្សេងៗ

កម្រិតថ្នាក់ ៖ ខ្ពស់

រយៈពេល ៣០នាទី

## I. វត្ថុបំណង

- វិជ្ជាសម្បទា ៖ កុមារប្រាប់បានពីស្លាកសញ្ញាផ្សេងៗ បានត្រឹមត្រូវតាមរយៈការសង្កេតនិងពន្យល់ណែនាំរបស់គ្រូ។
- បំណិនសម្បទា ៖ កុមារកំណត់បានពីស្លាកសញ្ញាផ្សេងៗ បានត្រឹមត្រូវតាមរយៈការសង្កេតនិងអនុវត្តផ្ទាល់។
- ចរិយាសម្បទា ៖ បណ្ដុះស្មារតីកុមារមានការប្រុងប្រយ័ត្ន ចេះគោរពស្លាកសញ្ញាផ្សេងៗក្នុងពេលធ្វើដំណើរ។

## II. សម្ភារៈឧបទេស

- ចំពោះគ្រូ ៖ ប័ណ្ណរូបភាព
- ចំពោះសិស្ស ៖ ..................................................
- ការរៀបចំ និងទីកន្លែង ៖ កុមារអង្គុយជាកន្លះរង្វង់ (U)

## III. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
| --- | --- | --- |
| | ជំហានទី ១ (លំនឹកថ្នាក់) | |
| – តើកូនៗមកជុំគ្នាហើយឬនៅ? ,អោយមេក្រុមពិនិត្យសមាជិកក្នុងក្រុម។<br>– តើកូនមានលាងសម្អាតដៃហើយឬនៅ?<br>– តើមានសម្លៀកបំពាក់ស្អាតហើយឬនៅ? | – ពិនិត្យអវត្តមាន<br>– ពង្រឹងវិន័យ អនាម័យ និងសណ្តាប់ធ្នាប់<br>– ប្រមូលអារម្មណ៍កុមារ | – មេក្រុមពិនិត្យសមាជិកក្នុងក្រុមហើយរាយការណ៍<br>– បង្ហាញដៃដែលលាងសម្អាតរួច (ដៃទាំងពីរដាក់លើតុ)<br>– ពិនិត្យសម្លៀកបំពាក់រៀងៗខ្លួន។ |
| – កូនទាំងអស់គ្នាសូត្រកំណាព្យពេលដើរតាមផ្លូវជាមួយអ្នកគ្រូទាំងអស់គ្នា | – បទ «ពេលដើរតាមផ្លូវ» | – សូត្រតាមទាំងអស់គ្នា |
| | ជំហានទី ២(រំលឹកមេរៀនចាស់) | |
| – តើកាលពីថ្ងៃមុនអ្នកគ្រូនាំកូនរៀនមេរៀនវិទ្យាសាស្ត្រអ្វីដល់កូន?<br>– ពេលកូនធ្វើដំណើរតាមដងផ្លូវ តើកូនមានឃើញអ្វីខ្លះ? | * រំលឹកមេរៀនចាស់<br>- ............................<br>* ទំនាក់ទំនងមេរៀនថ្មី<br>-មានផ្ទះ ឡាន ម៉ូតូ ភ្លើងស្តុប....... | - ឆ្លើយ<br>– អោយកូនសិស្សឆ្លើយរៀបរាប់ |
| | ជំហានទី ៣ (មេរៀនថ្មី) | |
| – ថ្ងៃនេះអ្នកគ្រូមានមេរៀនវិទ្យាសាស្ត្រថ្មីមួយមកបង្រៀនដល់កូន | – សង្កេត «ស្លាកសញ្ញានានា» | – ស្តាប់ |

| | | |
|---|---|---|
| – អ្នកគ្រូមានរូបភាពជាច្រើន មកបង្ហាញដល់កូនៗ<br>– ប្រាប់ចំណងជើងមេរៀន និងអោយកុមារថាតាម<br>– បំផុសគំនិតអោយកុមាររៀបរាប់ពីអ្វីដែលពួកគេបានឃើញក្រោមការបំពេញបន្ថែមរបស់គ្រូ៖<br><br>* ស្លាកសញ្ញាបន្ទប់ទឹក : មនុស្សស្រី-ប្រុស ដែលមាននៅតាមទីកន្លែងសាធារណៈដូចជា សាលារៀន មន្ទីពេទ្យ វត្ត ការ៉ាសសាំង .........<br><br>* ស្លាកសញ្ញាប្រយ័ត្នខាងមុខមានភ្លើងសញ្ញាចរាចរណ៍ : នៅផ្លូវប្រសព្វបំបែកជាបួន ឬជាបី មានបីពណ៌<br><br>* ស្លាកសញ្ញាប្រយ័ត្នខាងមុខអាចមានកុមារឆ្លងកាត់: មានតាមដងផ្លូវជាពិសេសសាលារៀន.............. | – បង្ហាញសម្ភារៈដោយពញ្ញាក់អារម្មណ៍<br>– ប្រាប់ចំណងជើងមេរៀន<br>– បង្ហាញរូបភាពម្តងមួយៗ<br><br>បន្ទប់ទឹកប្រុស<br>–<br><br>បន្ទប់ទឹកស្រី<br><br>ស្លាកសញ្ញាប្រយ័ត្នខាងមុខមានភ្លើងសញ្ញាចរាចរណ៍<br><br>ស្លាកសញ្ញាប្រយ័ត្នខាងមុខអាចមានកុមារឆ្លងកាត់ | – សង្កេតមើល<br>– ស្តាប់និងអានចំណងជើងមេរៀន<br>– កុមាររៀបរាប់ពីអ្វីដែលគេបានឃើញ<br>- ស្តាប់ |

| | | |
|---|---|---|
| * ស្លាកសញ្ញាប្រយ័ត្នខាងមុខអាចមានសត្វពាហនៈឆ្លងកាត់ : មាននៅតាមកន្លែងកសិដ្ឋានចិញ្ចឹមសត្វ ឬតំបន់ដែលមានសត្វ គោ ក្របី.......ឆ្លងកាត់ | <br>ស្លាកសញ្ញាប្រយ័ត្នខាងមុខ អាចមានសត្វពាហនៈឆ្លងកាត់ | - ស្តាប់ |
| * ស្លាកសញ្ញាប្រយ័ត្នខាងមុខមានរថភ្លើងឆ្លងកាត់ដោយគ្មានរបាំងការពារ : ផ្លូវដែលមានរថភ្លើងឆ្លងកាត់ផ្លូវ | <br>ស្លាកសញ្ញាប្រយ័ត្នខាងមុខមានរថភ្លើងឆ្លងកាត់ដោយគ្មានរបាំងការពារ | - ស្តាប់ |
| * ស្លាកសញ្ញាប្រយ័ត្នខាងមុខមានរង្វង់មូល : ផ្លូវចំណុចប្រសព្វច្រើនតម្រូវអោយបើកបរជារង្វង់តាមទិសដៅដែលចង់ធ្វើដំណើរ | <br>ស្លាកសញ្ញាប្រយ័ត្នខាងមុខមានរង្វង់ | - ស្តាប់ |

| | | |
|---|---|---|
| * ស្លាកសញ្ញាហាមចូលចំពោះយានជំនិះគ្រប់ប្រភេទ : តែងតែប្រទះឃើញស្លាកសញ្ញានេះតាមទីកន្លែងដូចជា បិទផ្លូវ ការដ្ឋានសាងសងផ្សេងៗ រោងចក្រ ........ | <br>ស្លាកសញ្ញាហាមចូលចំពោះយានជំនិះគ្រប់ប្រភេទ | - ស្តាប់ |
| * ស្លាកសញ្ញា «ឈប់» : អ្នកបើកបរត្រូវឈប់ទោះបីមាន ឬគ្មានយានជំនិះផ្សេងទៀតឆ្លងកាត់នៅខាងមុខក៏ដោយ។ អ្នកបើកបរអាចធ្វើដំណើរទៅមុខបានលុះត្រាតែផ្លូវត្រូវដែលឆ្លងកាត់នោះទំនេរ។ ជាទូទៅ ស្លាកសញ្ញា ឈប់ តែងតែមាននៅត្រង់ផ្លូវប្រសព្វ។ | <br>ស្លាកសញ្ញា «ឈប់» | |
| * ស្លាកសញ្ញា «មន្ទីរពេទ្យ» ស្លាកសញ្ញានេះតែងតែប្រទះឃើញតាមដងផ្លូវដែលមានមន្ទីរពេទ្យនៅជិតផ្លូវ |  | - ស្តាប់ |

| | | |
|---|---|---|
| * ស្លាកសញ្ញា កន្លែងសង្គ្រោះបន្ទាន់ សញ្ញានេះតែងតែប្រទះឃើញនៅមន្ទីពេទ្យ គ្លីនិក ឡានសង្គ្រោះបន្ទាន់.......<br><br>– ក្រៅពីស្លាកសញ្ញាទាំងនេះ នៅមានស្លាកសញ្ញាចរាចរណ៍ជាច្រើនទៀត ដែលកូនៗត្រូវតែគោរព និងអនុវត្តតាម មិនថានៅតាមទីសាធារណៈ ឬធ្វើដំណើរតាមដងផ្លូវនោះទេ ត្រូវគោរពជានិច្ច ដើម្បីធ្វើអោយកូនៗក្លាយជាកូនល្អ ពលរដ្ឋល្អ និងជាពិសេសជៀសពីគ្រោះថ្នាក់ផ្សេងៗ បានទៀតផង។ | <br>ស្លាកសញ្ញា កន្លែងសង្គ្រោះបន្ទាន់<br><br>– សង្ខេបខ្លឹមសារមេរៀនសំខាន់របស់មេរៀន | - ស្តាប់<br><br>– ស្តាប់ដោយយកចិត្តទុកដាក់ |
| <u>ជំហានទី ៤ (ពង្រឹងចំណេះដឹង)</u> | | |
| – តើមុននេះអ្នកគ្រូបានបង្រៀនមេរៀនភាសាខ្មែរអ្វីដល់កូនៗ? | – វិទ្យាសាស្រ្ត : សង្កេតស្លាកសញ្ញាផ្សេងៗ<br>ស្លាកសញ្ញា «មន្ទីពេទ្យ» | – ឆ្លើយ |

| | | |
|---|---|---|
| – អ្នកគ្រូអោយកុមារម្តងពីរនាក់ឡើងមកចង្អុលរូបភាពស្លាកសញ្ញាប្រណាំងគ្នា។ | – អោយកុមារឡើងអនុវត្តលើក្តារខៀន | – កុមារ ២ ឬ៤នាក់ត្រូវឡើង |
| <u>ជំហានទី ៥ (កិច្ចការផ្ទះ និងបណ្តាំផ្ញើរ)</u> | | |
| – អ្នកគ្រូសប្បាយចិត្តណាស់ដោយឃើញកូនៗមានភាពឆ្លាតវៃ និងយកទុកដាក់ក្នុងពេលរៀន<br>– ពេលត្រឡប់ទៅផ្ទះកូនៗកុំភ្លេចជម្រាបម៉ាក់ប៉ាកូនៗថាកូនបានរៀន មេរៀនថ្មីមួយទៀតគឺ វិទ្យាសាស្ត្រ គឺ សង្កេត «ស្លាកសញ្ញាផ្សេងៗ» ផងណា | – លើកទឹកចិត្ត និងសរសើរ<br>– បណ្តាំផ្ញើរ និងកិច្ចការផ្ទះ | – ស្តាប់ដោយសប្បាយរីករាយ<br>– យកចិត្តទុកដាក់ស្តាប់ ការណែនាំរបស់អ្នកគ្រូ |

មតិយោបល់ :

ថ្ងៃទី......... ខែ......... ឆ្នាំ...........

គ្រូប្រចាំថ្នាក់

បានពិនិត្យត្រឹមត្រូវ

ថ្ងៃទី......... ខែ......... ឆ្នាំ...........

នាយិកាសាលា